# ៨. បញ្ហាសិទ្ធិមនុស្សនៅកំរិតម៉ាក្រូ

មានភាពខុសគ្នាជាច្រើនក្នុងការប្រើប្រាស់ពាក្យដើម្បីផ្សព្វផ្សាយយុទ្ធសាស្ត្រអប់រំនៅជុំវិញពិភពលោក ដែលឆ្លុះបញ្ចាំងអំពីអត្ថន័យ និងវិធីសាស្ត្រទូលំទូលាយនៃការអប់រំ។ ការអប់រំអាចកំណត់និយមន័យតាមរបៀបខុសគ្នាយ៉ាងច្រើនពីចក្ខុវិស័យផ្សេងគ្នា : ជាមធ្យោបាយបង្កើនសមត្ថភាពរកប្រាក់ចំនូល ឬសំរាប់កាត់បន្ថយអត្រាកំណើត។ សេដ្ឋវិទូឲ្យនិយមន័យអប់រំថាជាប្រសិទ្ធភាពផលិតរបស់ធនធានមនុស្ស និងចាត់ទុកវិសាលភាពសិទ្ធិមនុស្សជាជំនួយពីខាងក្រៅជួយឲ្យសំរេចការងារនេះ។ និយមន័យធ្វើឲ្យការអប់រំមានអត្ថន័យខុសគ្នាដែលជនគ្រប់រូបត្រូវបានគេមើលឃើញថាជាកម្មវត្ថុនៃសិទ្ធិមនុស្ស។

**បញ្ហាបសិទ្ធិមនុស្សក្នុងវិស័យអប់រំ**

ច្បាប់សិទ្ធិមនុស្សអំពាវនាវឲ្យមានការបញ្ជ្រាបសិទ្ធិមនុស្សតាមរយៈដំណើរការរៀន និងបង្រៀន។ តាមរយៈចក្ខុវិស័យនេះ ការអប់រំគឺជាគោលដៅចុងក្រោយ និងជាមធ្យោបាយដើម្បីឈានទៅសំរេចគោលដៅផ្សេងទៀត។ លក្ខណៈបែបនេះ ផ្ទុយគ្នាស្រលះពីយុទ្ធសាស្ត្រធនធានមនុស្ស ដូចចង្អុលបង្ហាញដោយឧបសគ្គទាំងឡាយដែលកុមារពិការកំពុងជួបប្រទះនៅក្នុងប្រទេសមួយចំនួន។ ប្រាក់ដែលត្រូវចំណាយដើម្បីឆ្លើយតបនឹងតម្រូវការរបស់កុមារពិការរាងកាយលើថ្លៃចំណាយ ដូចជា រទេះរុញ សម្ភារសិក្សាពិសេស ។ត្រូវបានចាត់ទុកដោយអាជ្ញាធរថា ជាការចំណាយច្រើនហួសហេតុ បើប្រៀបធៀបនឹងប្រាក់ដែលត្រូវរកបានមកវិញតិចតួចដោយកុមារពិការទាំងអស់នេះពេល គេធ្វើការ។

ការពន្យល់ហេតុផលបែបនេះគឺជាការពន្យល់ដែលមានលក្ខណៈខុសពីការពន្យល់របស់សិទ្ធិមនុស្ស ដែលថា មនុស្សទាំងអស់មានតម្លៃដូចគ្នា នឹងការអប់រំសំរាប់ទាំងអស់គ្នាមានលក្ខណៈសំខាន់ដូចគ្នា។

ភាពខុសគ្នានៃខ្លឹមសារនេះចង្អុលបង្ហាញតម្រូវការឲ្យមានយុទ្ធសាស្ត្រសិទ្ធិមនុស្សពិស្តារ និងស៊ីចង្វាក់គ្នាសំរាប់ការអប់រំដើម្បីបញ្ចូលសិទ្ធិមនុស្សនៅក្នុងយុទ្ធសាស្ត្រ និងយន្តការត្រួតពិនិត្យជាតិ និងអន្តរជាតិ។

**សកលភាវូបនីយកម្ម និងជាតិភាវូបនីយកម្ម**

ទំនាក់ទំនងរវាងនិន្នាការទាំងពីរគឺសកលភាវូបនីយកម្ម និងជាតិភាវូបនីយកម្មក៏មានទម្ងន់លើការអប់រំផ្អែកលើសិទ្ធិដែរ។ នៅកំរិតសកល យុទ្ធសាស្ត្រអប់រំមានចាប់តាំងពីការខិតខំប្រឹងប្រែងផ្តល់ការអប់រំនៅបឋមសិក្សាដល់កុមារគ្រប់រូបដើម្បីធានាគុណភាពនៃសេវាអប់រំដែលត្រូវបានគេធ្វើជំនួញជាអន្តរជាតិ។ នៅកំរិតជាតិ ការអប់រំស្ថិតនៅក្រោមការទទួលខុសត្រូវរបស់អាជ្ញាធរតំបន់ និងមូលដ្ឋាន។ និន្នាការ ដែលចេះតែកើនឡើងឆ្ពោះទៅរកវិមជ្ឈការនៅក្នុងប្រទេសជាច្រើនបង្កើតជាយន្តការត្រួតពិនិត្យមើលតាមមូលដ្ឋានលើគោលនយោបាយអប់រំ។ សកលភាវូបនីយកម្មធ្វើឲ្យប៉ះពាល់ផ្នែកខាងលើនៃការអប់រំ ដោយសាកលវិទ្យាល័យក្លាយជាសេវាពាណិជ្ជកម្មនៅក្នុងប្រទេសជាច្រើន និងនៅទូទាំងអន្តរជាតិ។ ប៉ុន្តែការអប់រំនៅបឋមសិក្សានៅមានលក្ខណៈមូលដ្ឋាននៅឡើយ។ ភាសា ទំនៀមទំលាប់ និងវប្បធ៌មមូលដ្ឋានត្រូវបានផ្សព្វផ្សាយពីមួយជំនាន់ទៅមួយជំនាន់ទៀតនៅតាមមូលដ្ឋានដើម្បីធានាភាពគង់វង្សនៃ ភាសា ទំនៀមទំលាប់ និងវប្បធម៌ មូលដ្ឋានរបស់គេ។

ស្ថាប័នជាតិ និងអន្តរជាតិជាច្រើនសហការគ្នាលើវិស័យអប់រំលើផ្នែកផ្សេងៗចាប់តាំងពីហិរញ្ញវត្ថុទៅយេនឌ័រទៅការមានការងារធ្វើ របស់និស្សិតរៀនចប់។ ទោះបីជាមានការសហការគ្នាយ៉ាងនេះក្តី ផ្នែកផ្សេងទៀតនៃការអប់រំត្រូវដោះស្រាយដោយភ្នាក់ងាររដ្ឋាភិបាល ឬឯកជន។ គុណសម្បត្តិពិសេសរបស់ការអប់រំផ្អែកលើសិទ្ធិគឺក្របខ័ណ្ឌផ្លូវច្បាប់ពិស្តារដែលអាចប្រើប្រាស់បានដោយមិនគិតពីការបែងចែកទំនួលខុសត្រូវតាមខ្សែទទឹង ឬខ្សែ

បណ្តោយនោះទេ។ យុទ្ធសាស្ត្របែបនេះជាយុទ្ធសាស្ត្រដែលនាំមកនូវនិរន្តរភាព។ វាមានទំនាក់ទំនងនឹងសិទ្ធិទទួលយកការអប់រំរបស់បុគ្គលដោយសមស្របទៅនឹងកាតព្វកិច្ចរបស់រដ្ឋាភិបាល ដោយផ្សាភ្ជាប់ការផ្តល់សិទ្ធិ និង អំណាច និងការទទួខុសត្រូវ។

សិទ្ធិមនុស្សមានទំនាក់ទំនងជាមួយផ្នែកផ្សេងៗទៀតរបស់រដ្ឋាភិបាល និងបន្តទៅផ្នែកផ្សេងទៀតរបស់សង្គម។ ក្នុងន័យនេះ ការបញ្ជ្រាបទាមទារឲ្យមានយុទ្ធសាស្ត្រស៊ីចង្វាក់គ្នារវាងអង្គការច្បាប់ និងស្ថាប័ននានា។ ជាពិសេសច្បាប់ទាំងឡាយត្រូវតែពង្រីកដើម្បីរួមបញ្ចូលយុទ្ធសាស្ត្រម៉ាក្រូសេដ្ឋកិច្ច និងអប់រំដើម្បីលុបបំបាត់ឧបសគ្គកង្វះហិរញ្ញវត្ថុសំរាប់វិស័អប់រំ។

នៅក្នុងប្រទេសនីមួយៗ ប្រាក់ពន្ធដែលទ្រទ្រង់ការអប់រំ និងការអនុវត្តគោលនយោបាយត្រូវមានការចូលរួមពីសហគមន៍ទាំងមូល។ នៅក្នុងពិភពលោកទាំងមូល ការធ្វើសកលកម្មសិទ្ធិអប់រំផ្អែកលើការសហការជាសកលដើម្បីឲ្យមានការចូលរួមដោយស្មើភាពគ្នា ដោយការផ្តល់ជំនួយដល់ប្រទេសដែលមានការរីកចំរើនផ្នែកសេដ្ឋកិច្ចតិចតួច។

ទំហំនៃបេសកកម្មសិទ្ធិមនុស្សត្រូវពង្រីកឲ្យហួសពីប្រព័ន្ធច្បាប់ ព្រោះគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និង នយោបាយអាចធ្វើឲ្យប៉ះពាល់សិទ្ធិទទួលយករបស់មនុស្សម្នាក់។ ការគិតទុកពីផលប៉ះពាល់របស់សិទ្ធិមនុស្សនៃគោលនយោបាយអ្វីមួយគឺជាវិធីចាំបាច់ក្នុងដំណើរការតាមដានត្រួតពិនិត្យ។

ការតម្រែតម្រង់យុទ្ធសាស្ត្រអភិវឌ្ឍន៍សកលឆ្ពោះទៅកាត់បន្ថយភាពក្រីក្រផ្តល់ឱកាសធំធេងដើម្បីបញ្ជ្រាបសិទ្ធិមនុស្ស និងសមភាពយេនឌ័រទៅក្នុងការអប់រំ។ គេឃើញមានទំនាក់ទំនងយ៉ាងខ្លាំងរវាងភាពក្រីក្រ និងការបដិសេធសិទ្ធិមិនឲ្យទទួលការអប់រំ និងការរើសអើងយេនឌ័រ។

ការបាត់បង់ឱកាសចូលរៀន និងការបដិសេធសិទ្ធិមិនឲ្យធ្វើការ និងសិទ្ធិនៅកន្លែងធ្វើការធ្វើឲ្យស្ត្រីពឹងផ្អែកប្តី ឬសមាជិកគ្រួសារប្រុសលើផ្នែកហិរញ្ញវត្ថុ។ សភាពបែបនេះនឹងបង្កើនភាពក្រីក្ររបស់កុមារី និងស្ត្រី និងធ្វើឲ្យកុមារី និង ស្ត្រីក្លាយជាអ្នកដែលមិនទទួលបានការយកចិត្តទុកដាក់ពីសង្គម។ ទំនាក់ទំនងរវាងភាពក្រីក្រ និងការមិនយកចិត្តទុកដាក់ ចំពោះកុមារី និងស្ត្រីផ្តល់ហេតុផលសមរម្យសំរាប់ការអប់រំដោយផ្អែកលើសិទ្ធិ។ ការបញ្ជ្រាបសិទ្ធិមនុស្សបំពេញបន្ថែម ពេញលេញលើការយកចិត្តទុកដាក់លើមធ្យោបាយនៃការអប់រំពោលគឺអាទិភាពសំរាប់កុមារគ្រប់រូបដើម្បីចាប់ផ្តើម និងបញ្ចប់បឋមសិក្សាដោយសួរសំនួរថា : តើការអប់រំសំរាប់អ្វី?

គោលបំណងសំខាន់មួយនៃការអប់រំគឺការផ្តល់ចំនេះដឹងអំពីសិទ្ធិមនុស្ស ជាពិសេសសិទ្ធិរបស់កុមារី និង ស្ត្រី។ នៅទន្ទឹមនឹងការរីកចំរើន សន្ទឹកសន្ទាប់លើបញ្ហានេះនៅក្នុងប្រទេសមួយចំនួននៅជុំវិញពិភពលោក ប្រទេសជាច្រើនទៀតហាក់ដូចជាពុំទាន់ដំណើរការនៅឡើយ ដូចដែលបញ្ជាក់នៅក្នុងរបាយការណ៍របស់ប្រទេសប៉ាពូញូហ្គីនី និងកោះសូឡូម៉ុង :

"រដ្ឋធម្មនុញ្ញប្រទេសប៉ាពូញូហ្គីនី ច្បាប់ក្នុងស្រុក និងកតិកាសញ្ញាពុំមានអត្ថន័យអ្វីសំរាប់កុមារនៅតាមជនបទទេ។ ការទទួលយកទំនៀមទំលាប់ប្រពៃណីបុរាណយ៉ាងទូលំទូលាយទាក់ទងនឹងអាយុរៀបការ និង បញ្ហាផ្សេងទៀតទាក់ទងនឹងការការពារកុមារ ធ្វើឲ្យច្បាប់ក្នុងស្រុក និងកតិកាសញ្ញាអន្តរជាតិពុំមានសារៈសំខាន់

សំរាប់ជីវិតរបស់កុមារនៅក្នុងតំបន់ដាច់ស្រយាល និងភូមិបុរាណ។ ការពិតនេះបង្កើតបញ្ហាជាច្រើន ទោះបីគេចាត់ទុកថាជាបញ្ហាបណ្ដោះអាសន្នក៏ដោយ។"[៧៤]

"នៅក្នុងតំបន់មួយចំនួននៃកោះសូឡូម៉ុង ការរៀបការតាមបែបប្រពៃណីអនុញ្ញាតឲ្យកុមារីក្មេងរៀបការជាមួយនឹងបុរសដែលឪពុកម្ដាយបានជ្រើសរើសឲ្យ បើទោះជានាងមិនស្រលាញ់សោះក៏ដោយ។ នៅក្នុងករណីបែបនេះ ការគាំទ្រ និងការការពារផលប្រយោជន៍ស្ត្រីត្រូវបានរារាំង ដោយហេតុផលច្រើនយ៉ាង។ អ្នកដែលចង់ជួយនឹងត្រូវគេហាមឃាត់មិនឲ្យជ្រៀតជ្រែកក្នុងកិច្ចការគ្រួសាររបស់អ្នកដទៃ ឬអ្នកដែលចង់ជួយនោះមិនចង់ធ្វើឲ្យមានការបែកបាក់ក្នុងគ្រួសារនៅក្នុងសហគមន៍របស់គេទេ ឬអ្នកដែលប្រព្រឹត្តិទាំងនោះមិនដឹងពីសិទ្ធិស្របច្បាប់ របស់កុមារដែលមាននៅក្នុងរដ្ឋធម្មនុញ្ញទេ។ ទោះបីជាស្ថានភាពបែបសន្មត់ដែលយើងលើកមកបង្ហាញនេះជារឿងទូទៅហើយក៏ដោយ ក៏ការចាត់ការដោះស្រាយតាមផ្លូវច្បាប់នៅមិនទាន់មានប្រសិទ្ធភាពនៅឡើយ"។[៧៥]

### ៨.១. តើការអប់រំនៅសាលាដូចគ្នា ឬសាលាខុសគ្នា ?

ច្បាប់ និងរដ្ឋធម្មនុញ្ញជាតិខុសគ្នាយ៉ាងខ្លាំងទាក់ទងទៅនឹងសំនួរដែលសួរថាតើគេគួរអប់រំកុមារជាមួយគ្នាឬយ៉ាងណានោះ។ ប្រទេសខ្លះមានបណ្ដាញសាលារដ្ឋមានលក្ខណៈដូចគ្នាទូទាំងប្រទេស និងប្រទេសខ្លះទៀតជំរុញឪពុកម្ដាយ និងសហគមន៍ឲ្យបង្កើតសាលាច្រើនបែប។ នៅប្រទេសឥណ្ឌូណេស៊ី ច្បាប់ឆ្នាំ ១៩៩៩ ស្ដីពីសិទ្ធិមនុស្សសន្យាថា *"កុមារទាំងអស់មានសិទ្ធិចូលរៀនក្នុងសាលាដែលមានប្រយោជន៍ដល់កុមារសមស្របនឹងទេព្យកោសល្យ និងសមត្ថភាពរបស់កុមារ"*។ ប្រព័ន្ធអប់រំរបស់រដ្ឋ និងឯកជនយកថ្លៃ និងមិនយកថ្លៃ កាន់សាសនា និង មិនកាន់សាសនាត្រូវបានធានានៅក្នុងច្បាប់ជាតិ ដែលច្បាប់នេះក៏ធានាឲ្យមានសេរីភាពក្នុងការប្រមូលថវិកាសំរាប់ *"ការអប់រំ និងសាលាឯកជនផងដែរ"*។[៧៦]

***សាលា សាសនា ឬមិនមែន សាសនា***

ទាក់ទងនឹងសាលាសាសនា ឬមិនមែនសាសនា រដ្ឋធម្មនុញ្ញខ្លះបញ្ជាក់ថា ការអប់រំអាចផ្ដល់ដោយសហគមន៍សាសនា ហើយប្រទេសខ្លះទៀតឲ្យមានបង្រៀនសាសនានៅក្នុងសាលារដ្ឋតែម្ដង។ ឧទាហរណ៍ : រដ្ឋធម្មនុញ្ញរបស់ម៉ាឡេស៊ីឆ្នាំ ១៩៥៧ និងច្បាប់រដ្ឋធម្មនុញ្ញសិង្ហបុរីឆ្នាំ ១៩៦៣ បញ្ជាក់ថា "គ្រប់ក្រុមសាសនាទាំងអស់មានសិទ្ធិបង្កើត និងថែរក្សាស្ថាប័នសំរាប់ការអប់រំកុមារតាមសាសនារបស់ខ្លួន និងពុំមានការរើសអើងដោយសារតែការប្រកាន់ជំនឿសាសនាខុសគ្នានោះទេ"។

យុទ្ធសាស្ត្របែបនេះធានាសុវត្ថិភាពអត្តសញ្ញាណសាសនា ឬភាសានៅក្នុងសហគមន៍ ប៉ុន្តែក៏បង្កជាបញ្ហាធំទៅៗ ផងដែរបើតាមទស្សនៈសិទ្ធិបុគ្គល និងបង្កការលំបាកចំពោះតួនាទីអប់រំដែលចាត់ទុកជាទ្រព្យសម្បត្តិសាធារណៈ។ ការមានសាលារដ្ឋ និងឯកជននៅពេលទន្ទឹមគ្នាធ្វើឲ្យមានបញ្ហាធំៗ ២ :

74 Report by Papua New Guinea, CRC/C/28/Add.20 of 21 July 2003, para. 80.

75 Report by Solomon Islands, CRC/C/51/add.6 of 12 July 2002, para. 476.

76 The House of Representatives of the Republic of Indonesia - Legislation Number 39 of 1999 Concerning Human Rights, Jakarta, 23 September 1999, State Gazette of the Republic of Indonesia No. 165 of 1999.

• ទីមួយ : ការបែងចែកសាលារដ្ឋ/ឯកជនធ្វើឲ្យមានវិសមភាពខាងសម្ភារនៅក្នុង ឬរវាងសហគមន៍។ គម្លាតនៃភាពក្រីក្រជួនគ្នាជាមួយនឹងការបែងចែកសញ្ជាតិ ជនជាតិភាគតិច សាសនា និងភាសានៅក្នុងសង្គម។ ចាំបាច់គេត្រូវពិនិត្យឲ្យបានច្បាស់លាស់ពីគំរូនៃការអប់រំ និងថាតើគំរូនេះអាចជួយលុបបំបាត់ការរើសអើង និងជំរុញឲ្យមានការប្រើប្រាស់វិធីសាស្ត្រដែលមានការចូលរួម។

• ទីពីរ : រដ្ឋាភិបាលត្រូវគេមើលឃើញថាមានការទទួលខុសត្រូវកាន់តែខ្លាំងនៅក្នុងការអប់រំ : ក្រៅពីធានាថា ស្ថាប័នអប់រំទាំងអស់អនុវត្តទៅតាមស្តង់ដាគុណភាពដែលមានចែងរួចហើយ ស្ថាប័នអប់រំទាំងនោះក៏ត្រូវតែធានាថា តែសំរេចឲ្យបានដោយការប្តេជ្ញាចិត្តច្បាស់លាស់ចំពោះសិទ្ធិមនុស្ស។ ខ្លឹមសារកម្មវិធីអប់រំ និងសៀវភៅសិក្សា វិធីសាស្ត្រនៃការបង្រៀន ឬរដ្ឋបាលវិន័យសាលាអាចមានទំនាស់ជាមួយសិទ្ធិមនុស្សដែលគេទទួលស្គាល់ជាអន្តរជាតិជាពិសេសទាក់ទងនឹងសិទ្ធិកុមារ។

ដើម្បីបំពេញកាតព្វកិច្ចសិទ្ធិមនុស្ស រដ្ឋាភិបាលត្រូវថ្លឹងថ្លែងទម្ងន់ប៉ះពាល់នៃប្រព័ន្ធសាលារៀនខុស ៗគ្នាឲ្យបានត្រឹមត្រូវ និងប្រុងប្រយ័ត្នបំផុតដើម្បីសំរេចការអប់រំសំរាប់ទាំងអស់គ្នា។ យើងបានពន្យល់ពីខាងដើមរួចហើយអំពីគុណសម្បត្តិ និងគុណវិបត្តិរបស់សាលារៀនជាមួយគ្នា និងសាលាដាច់ដោយឡែកពីគ្នា និងពីផលវិបាកដែលក្មេងស្រីត្រូវជួបប្រទះ បើក្មេងស្រីគ្មានឱកាសបានទទួលការសិក្សា ក្មេងស្រីនឹងគ្មានឱកាសមានការងារធ្វើ។ ភាពគ្មានការងារធ្វើនឹងធ្វើឲ្យក្មេងស្រី និងគ្រួសារកាន់តែក្រីក្រ។ ការខកខានមិនបានទទួលស្គាល់សិទ្ធិមូលដ្ឋានចាប់គិតពីសិទ្ធិចុះបញ្ជីកំណើតរហូតដល់សិទ្ធិជាពលរដ្ឋនឹងនាំទៅដល់ការបដិសេធន៍សិទ្ធិមិនឲ្យចូលរៀនរបស់កុមារ។ អ្នកបំរើតាមគ្រួសារអាចចាប់ផ្តើមនៅអាយុ ៤ ឆ្នាំ ហើយយ៉ាងហោចណាស់ ៨០ ភាគរយជាកុមារី ៧០ ភាគរយក្រុមគ្រួសាររងគ្រោះដោយសារការរើសអើង ដូចជា ជនជាតិភាគតិច និងជនផ្លាស់ទីលំនៅ។[77]

**ដំណាក់កាលក្នុងការឈានទៅសំរេចការអប់រំដែលរួមបញ្ចូលគ្នាទាំងអស់**

មានដំណាក់កាល ៤ យ៉ាង ដែលអាចកត់សំគាល់ថា ជាប្រព័ន្ធអប់រំដែលឆ្ពោះទៅបង្កើតគោលនយោបាយមួយដែលរួមបញ្ចូលគ្នាទាំងអស់។ ដំណាក់កាលទីមួយចាត់ទុកការអប់រំគឺជាសិទ្ធិ។ នៅកន្លែងដែលសិទ្ធិអប់រំត្រូវបានទទួលស្គាល់ពលរដ្ឋទាំងអស់នឹងមានឱកាសចូលរៀនកាន់តែច្រើន។ កុមារដែលពុំមានឯសារសំគាល់អត្តសញ្ញាណ នឹងត្រូវបានគេបដិសេធន៍ដោយប្រយោលមិនឲ្យចូលរៀននៅកន្លែងដែលគេទាមទារឲ្យមានឯកសារបែបនេះ។ នៅក្នុងប្រទេសជាច្រើនពលរដ្ឋដែលមិនមែនជាពលរដ្ឋរបស់ប្រទេសនោះត្រូវទទួលការបដិសេធន៍មិនឲ្យចូលរៀន។ កតិកាសញ្ញាស្តីពីសិទ្ធិកុមារសង្កត់ធ្ងន់ថា កុមារគ្រប់រូបមានសិទ្ធិចូលរៀន ប៉ុន្តែ របាយការណ៍របស់សន្និសញ្ញាសិទ្ធិមនុស្សបង្ហាញថា ការខកខានមិនបានទទួលសិទ្ធិពលរដ្ឋគឺជាឧបសគ្គ

**ការអប់រំជាសិទ្ធិ**

ស្របច្បាប់ដែលរឹកដុះដាលជាងគេបង្អស់ក្នុងការរារាំងកុមារមិនឲ្យទទួលបានសិទ្ធិអប់រំ។ កុមារី និងស្ត្រីជាអ្នករងគ្រោះច្រើនជាងគេ ពីព្រោះការរើសអើងយេនឌ័រច្រើនតែមានបង្កប់នៅក្នុងច្បាប់ដែលចែងថា កុមារអាចទទួលសិទ្ធិពលរដ្ឋបានពីឳពុក។

នៅពេលដែលគេទទួលស្គាល់ការអប់រំថា ជាសិទ្ធិមនុស្ស ដំណាក់កាលទី ២ ទាក់ទងនឹងការបែងចែកសញ្ជាតិ។ ក្នុងដំណាក់កាលនេះ កុមារីជនជាតិដើម កុមារពិការ ឬជនជាតិភាគតិចមានឱកាសចូលរៀនដែរ ប៉ុន្តែ រៀននៅសាលាដាច់ដោយឡែក ហើយមានលក្ខណៈអន់ថយជាង។

77 Sub-commission on the Promotion and Protection of Human Rights - Child domestic workers in Benin, Costa Rica and India. Submission by Anti-Slavery International to the 25th session of the Working Group on Contemporary Forms of Slavery, Geneva, 14-23 June 2000.

**ដំណើរឆ្ពោះទៅរកការបញ្ចូលគ្នាទាំងអស់**

ដំណាក់កាលទី ៣ ទាក់ទងនឹងការខិតចេញពីការបែងចែកដាច់ពីគ្នាឆ្ពោះទៅរកការបញ្ចូលគ្នា។ ក្រុមថ្មីដែលបានបញ្ចូលទៅក្នុងសាលាត្រូវសម្របសម្រួលដោយបោះបង់ចោលភាសាកំណើត ឬសាសនា និង ទីកន្លែងរស់នៅ បើសិនជាសាលារៀនស្ថិតនៅឆ្ងាយពីកន្លែងរស់នៅ។ ក្មេងស្រីត្រូវបានគេអនុញ្ញាតឲ្យចូលរៀន នៅក្នុងសាលាដែលកម្មវិធីសិក្សាត្រូវបានរៀបចំឡើងសំរាប់ក្មេងប្រុស។ ជនជាតិដើម និង ជនជាតិភាគតិចរៀន នៅសាលាដែលប្រើប្រាស់ភាសាយានមិនមែនជាភាសាកំណើត ហើយបង្រៀនកុមារអំពីមេរៀនប្រវត្តិសាស្ត្រ ដែលកុមារមិនទទួលស្គាល់។ ដំណើរការសិក្សាបែបនេះហាក់ដូចជាបង្ហាញពីការដាក់បញ្ចូលគ្នា ប៉ុន្តែវាគ្រាន់ តែមានឈ្មោះខុសពីអ្វីដែលគេធ្លាប់ស្គាល់នៅក្នុងការសិក្សាដាច់ដោយឡែកប៉ុណ្ណោះ។ អ្នកចំណូលថ្មីត្រូវសម្រប ខ្លួនទៅរកស្តង់ដាដែលមានទំនោរទៅរកបុរស ឬនិយាយភាសាផ្សេងពីភាសាកំណើត។

**សាលាឆ្លើយតបទៅនឹងពហុភាពនៃតម្រូវការ**

ដំណាក់កាលទី ៤ ទាមទារឲ្យសាលាសម្របសម្រួលតាមតម្រូវការខុស ៗគ្នារបស់សិស្ស។ ដំណាក់ កាលមុនៗទាមទារឲ្យសិស្សសម្របសម្រួលតាមអ្វីដែលសាលាមាន ប៉ុន្តែដំណាក់កាលចុងក្រោយនេះ ការអប់រំ ត្រូវសម្របសម្រួលឲ្យស៊ីនឹងផលប្រយោជន៏ និងចំណង់ចំណូលចិត្តរបស់សិស្ស។

ដំណាក់កាលខុស ៗគ្នាទាំងអស់នេះអាចសំគាល់ឃើញមាននៅក្នុងផ្នែកផ្សេង ៗនៃប្រព័ន្ធអប់រំនៅគ្រប់ ប្រទេសទាំងអស់នៅក្នុងពិភពលោក ប៉ុន្តែគេអាចនិយាយបានថាគ្មានប្រទេសណាមួយបំពេញបានពេញលេញនូវ កាតព្វកិច្ចសិទ្ធិមនុស្សអន្តរជាតិនៅក្នុងវិស័យអប់រំនៅឡើយ។ ដូច្នេះអង្គការសិទ្ធិមនុស្សអន្តរជាតិត្រូវតែ ប្រុងប្រយ័ត្ននៅពេលធ្វើការវាយតម្លៃការអនុលោមតាមសិទ្ធិមនុស្សអន្តរជាតិរបស់ប្រទេសណាមួយដើម្បីលើក ឡើងពីចំនុចខ្វះខាត និងសំណូមពរសំរាប់កែលំអ។

វាមានសារៈសំខាន់ខ្លាំងណាស់ដែលថា សិទ្ធិមនុស្សត្រូវបានគេទទួលស្គាល់ និងការពារលើមូលដ្ឋាន យូរអង្វែងមួយ ជាពិសេសត្រូវពិចារណាពីបំរែបំរួលច្បាប់នៅជុំវិញពិភពលោក។ ស្វ័យភាពក្នុងការបង្កើត ប្រព័ន្ធអប់រំ និងកម្មវិធីសិក្សាជាសេវារកស៊ីដោយគ្មានការហាមឃាត់ត្រូវតែមានតុល្យភាពជាមួយ និងសិទ្ធិ បុគ្គល ជាពិសេស សិទ្ធិទទួលបានការអប់រំដោយមិនគិតថ្លៃ។

## ៨.២. ការអប់រំរបស់រដ្ឋ ឬរបស់ឯកជន?

កាតព្វកិច្ចផ្តល់ការអប់រំដោយមិនបង់ថ្លៃត្រូវទាក់ទងនឹងការផ្តល់ការអប់រំនៅបឋមសិក្សាដោយ រដ្ឋាភិបាល តាមរយៈការសិក្សាសាលារដ្ឋ ឬសាលាឯកជនដែលទទួលជំនួយពីរដ្ឋ។ ប្រទេសខ្លះមានតែ សាលារដ្ឋ ហើយប្រទេសខ្លះទៀតមានតែសាលាឯកជន និងប្រទេសភាគច្រើន មានទាំងឯកជន និងរដ្ឋ។

ពាក្យថាសាលា "ឯកជន" មានន័យខុសគ្នាច្រើនយ៉ាងណាស់។ ក្នុងន័យទូលំទូលាយរបស់វា វាមានន័យ ថា "មិនមែនរបស់រដ្ឋ" ទោះបីជាសាលាខ្លះទទួលបានប្រាក់ឧបត្ថម្ភពីរដ្ឋមួយផ្នែក និងខ្លះទៀតទទួលការឧបត្ថម្ភ ទាំងស្រុង។ ការសន្និដ្ឋាននៅក្នុងពាក្យ "ឯកជន"គឺថា សាលាទាំងអស់គឺដើម្បីរកប្រាក់ចំណេញ តែតាមការពិត សាលាភាគច្រើនមិនដូច្នេះទេ។ ពាក្យនេះត្រូវគេប្រើទាំងការអប់រំក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ សាលាសាសនា និងមិនមែនសាសនា សាលាជនជាតិភាគតិច ឬជនជាតិដើម និងសាលាសំរាប់កុមារដែលមានតម្រូវការ ពិសេស។ សាលាឯកជនមួយចំនួនបំពេញបន្ថែមស្ថាប័នរដ្ឋ ហើយផ្តល់ការអប់រំសំរាប់ជនជាតិភាគតិច ឬ សាសនា ឬផ្តល់កន្លែងស្នាក់អាស្រ័យចំពោះកុមារដែលមានតម្រូវការពិសេស។ ខ្លះទៀតបង្កើតឡើងដើម្បីផ្តល់ ការអប់រំជំនួសឲ្យសាលារដ្ឋ។

សិទ្ធិទទួលការអប់រំទាមទារឲ្យរដ្ឋជាអ្នកផ្តល់ ព្រោះរដ្ឋជាអ្នកទទួលខុសត្រូវធានាថា ស្ថាប័នអប់រំ ទាំងអស់ត្រូវអនុលោមតាមស្តង់ដាច្បាប់ដែលបានចែងរួចហើយ។ ការប្រើប្រាស់សិទ្ធិរបស់ឪពុកម្តាយក្នុងការ ជ្រើសរើសការអប់រំសំរាប់កូនទាមទារឲ្យមានសាលារៀនច្រើន ហើយស្តង់ដានេះត្រូវតែធ្វើតាមនៅគ្រប់ ស្ថាប័នសិក្សាទាំងអស់ដើម្បីធានាថា ការអប់រំគឺជាទ្រព្យសម្បត្តិសាធារណៈបំរើផលប្រយោជន៍សាធារណៈ និង ការពារកុមារ ពីការកេងប្រវ័ញ្ច និងរំលោភបំពាន។

**សេរីភាពនីយកម្ម លើវិស័យអប់រំ**

ភាពបន្ទាន់ដើម្បីបញ្ជាក់បន្ថែមឡើងវិញពីសិទ្ធិទទួលការអប់រំបានធ្វើឡើងដោយការបន្តការចរចាស្តីពីសេរីភាពនៅក្នុងការធ្វើពាណិជ្ជកម្មសេវាអប់រំ។ អ្នករកស៊ីនាំសេវាអប់រំទៅផ្តល់នៅតាមបណ្តាប្រទេសនានាបានណែនាំពន្យល់ថាការអប់រំគឺជាសេវាដែលអាចធ្វើពាណិជ្ជកម្មជាលក្ខណៈអន្តរជាតិ។ ដូច្នេះ វាជាការសំខាន់ណាស់ដើម្បីកំណត់ខ្លឹមសារ និងវិសាលភាពរបស់ការអប់រំដែលជាទ្រព្យសម្បត្តិសាធារណៈបំរើផលប្រយោជន៍សាធារណៈនឹងត្រូវផ្តល់ឲ្យកុមារដោយមិនគិតថ្លៃ ទោះបីជាការអប់រំនេះអាចផ្តល់ដោយផ្នែកឯកជនសំរាប់គ្រួសារដែលអាចបង់ថ្លៃក៏ដោយ។

ដំណើរការក្នុងការប្រែក្លាយការអប់រំឲ្យទៅជាឯកជនបង្កើតឲ្យមានប្រព័ន្ធអប់រំពីរស្របគ្នាដោយមានគុណភាពពីរប្រភេទផ្សេងគ្នា។ សាលារដ្ឋនឹងមានងារជា "សាលារដ្ឋក្រីក្រសំរាប់អ្នកក្រ"។ ជំរើសយកការអប់រំដោយមិនគិតថ្លៃសំរាប់ឪពុកម្តាយភាគច្រើន "ពុំមែនមិនគិតថ្លៃនោះទេ" ព្រោះថា ទំនួលខុសត្រូវរបស់ឪពុកម្តាយត្រូវផ្តល់សម្ភារសិក្សាឲ្យកូន ហើយពេលកូនទៅរៀន ឪពុកម្តាយត្រូវបាត់បង់កម្លាំងពលកម្មក្នុងគ្រួសារ។ ការចំណាយរបស់ឪពុកម្តាយលើការអប់រំវាផ្ទុយនឹងច្បាប់សិទ្ធិមនុស្សអន្តរជាតិ ដែលទាមទារឲ្យរដ្ឋាភិបាលធានាផ្តល់ការអប់រំប្រកបដោយស្មើភាពគ្នាដល់កុមារគ្រប់រូប។

កិច្ចព្រមព្រៀងទូទៅស្តីពីពាណិជ្ជកម្មផ្តល់សេវាកម្មមានបញ្ញត្តិសំខាន់មួយ : វាមិនពង្រីកពាណិជ្ជកម្មផ្តល់សេវាទេ "ក្នុងការអនុវត្តអាជ្ញាធររដ្ឋាភិបាល"។ មាត្រា ១(៣)(ខ) និង(គ)នៅក្នុងកិច្ចព្រមព្រៀងចែងថា :

"(ខ) 'សេវា' រួមមានសេវានៅក្នុងផ្នែកទាំងអស់លើកលែងតែសេវាដែលផ្តល់ដោយការអនុវត្តអាជ្ញាធររដ្ឋាភិបាល

(គ) 'សេវា' ដែលផ្តល់ដោយការអនុវត្តរបស់អាជ្ញាធររដ្ឋាភិបាល មានន័យថា សេវាទាំងឡាយដែលផ្តល់ក្រៅពីគោលបំណងរកប្រាក់កំរៃ ឬមិនប្រកួតប្រជែងគ្នាជាមួយនឹងអ្នកផ្តល់សេវាផ្សេងទៀត។"

ការលើកឡើងនេះមានសក្តានុភាពគ្របដណ្តប់លើការអប់រំរបស់រដ្ឋដោយកាតព្វកិច្ច។ ដូច្នេះ រដ្ឋាភិបាលនីមួយៗអាចហាមឃាត់មិនឲ្យមានសេរីភាពនៅក្នុងការផ្តល់ការអប់រំឯកជននៅកំរិតបឋមសិក្សា ឬការសិក្សាដោយកាតព្វកិច្ចនោះទេ។ ឈ្មោះប្រទេសទាំង ១៩ នៅតារាងទី ១៩ បង្ហាញថាប្រទេសមួយចំនួនបានបញ្ចូលការអប់រំគ្រប់ផ្នែកដែលទទួលសេរីភាពក្នុងការផ្តល់ជាលក្ខណៈឯកជន។ ការបើកសិទ្ធិឲ្យការអប់រំដោយកាតព្វកិច្ចអាចមិនមានប្រសិទ្ធភាព បើសិនជាគ្មានថវិកាគ្រប់គ្រាន់ទេ។

78 World Trade Organization - Negotiating proposal for education services: Communication from New Zealand, S/CSS/W/93 of 26 June 2001.

ប្រទេសសមាជិកអង្គការពិភពលោកមួយចំនួនតូចប៉ុណ្ណោះបានខិតខំប្រឹងប្រែងផ្តល់សេរីភាពផ្នែកអប់រំនៅក្នុងប្រទេសគេ ហើយប្រទេសមួយចំនួនដែលបានធ្វើ គឺធ្វើតែមួយផ្នែកតូចប៉ុណ្ណោះ។ នេះបណ្តាលមក

**តារាង ១៩ : ការផ្តល់សេរីភាពក្នុងការអប់រំនៅក្រោមកិច្ចព្រមព្រៀង**

| សមាជិក WTO | ការប្តេជ្ញារបស់វិស័យនីមួយៗរបស់អប់រំ | | | | |
|---|---|---|---|---|---|
| | **បឋមសិក្សា** | **មធ្យមសិក្សា** | **ឧត្តមសិក្សា** | **អប់រំ មនុស្សចាស់** | **អប់រំ ផ្សេងៗទៀត** |
| Albania | X | X | X | X | X |
| Armenia | | | | | |
| Australia | | | | | |
| Austria | X | X | X | X | X |
| Bulgaria | X | X | X | X | X |
| China | X | X | X | X | X |
| Congo, D. R. | | | | | |
| Costa Rica | X | X | X | X | X |
| Croatia | | | | | |
| Czech Republic | X | X | X | X | X |
| Estonia | X | X | X | X | X |
| European Comm. | X | X | X | X | X |
| Gambia | X | X | X | X | X |
| Georgia | X | X | X | X | X |
| Ghana | | | | | |
| Haiti | | | | | |
| Hungary | X | X | X | X | X |
| Jamaica | X | X | X | X | X |
| Japan | X | X | X | X | X |
| Jordan | X | X | X | X | X |
| Kyrgyzstan | X | X | X | X | X |
| Latvia | X | X | X | X | X |
| Lesotho | X | X | X | X | X |
| Liechtenstein | X | X | X | X | X |
| Lithuania | X | X | X | X | X |
| Rep. of Macedonia | | | | | |
| Mali | | | | | |
| Mexico | X | X | X | X | X |
| Moldova | X | X | X | X | X |
| New Zealand | X | X | X | X | X |
| Norway | X | X | X | X | X |
| Oman | | | | | |
| Panama | X | X | X | X | X |
| Poland | X | X | X | X | X |
| Rwanda | | | | | |
| Sierra Leone | X | X | X | X | X |
| Slovak Republic | X | X | X | X | X |
| Slovenia | | | | | |
| Switzerland | X | X | X | X | X |
| Taiwan | X | X | X | X | X |
| Thailand | X | X | X | X | X |
| Trinidad & Tobago | | | | | |
| Turkey | X | X | X | X | X |
| USA | | | | | |
| សរុប | ៣១/៤៤ | ៣៦/៤៤ | ៣៥/៤៤ | ៣៤/៤៤ | ២០/៤៤ |

ពីការចរចាពីរឿងនេះទើបតែចាប់ផ្តើមប៉ុណ្ណោះ។ គួរឲ្យភ្ញាក់ផ្អើលណាស់ដែលថា ការផ្តល់សេរីភាពនេះគេបានធ្វើឡើង ស្មើគ្នាទាំងនៅបឋមសិក្សា និងនៅឧត្តមសិក្សាដូចឃើញក្នុងតារាងទី ១៩ ស្រាប់។ ការខិតខំបែបនេះមិនអាចអនុវត្តឲ្យបានត្រឹមត្រូវតាមផ្លូវច្បាប់បានទេ។